សៀវភៅនេះ សូមឧទ្ទិសដល់វិញ្ញាណខ័ន្ធលោក **សំ វាសនា** និងលោក **មាស ចិន្តាមុនី** ដែលបានទទួលមរណៈភាព ក្នុងបុព្វហេតុបេសកកម្មសិក្សាស្រាវជ្រាវ និង អភិរក្ស សត្វព្រៃនៅប្រទេសកម្ពុជា ។

This book is dedicated to Sam Veasna and Meas Chandamony, both of whom tragically died in the service of wildlife conservation in Cambodia.


សូមថ្លែងអំណរគុណយ៉ាងពិសេសចំពោះ ស្ថានទូតអង់គ្លេសប្រចាំនៅព្រះរាជណាចក្រកម្ពុជា ធនាគារពិភពលោក រដ្ឋាភិបាលប្រទេសហូឡង់ និងកម្មវិធីអាស៊ីរបស់អង្គការ IUCN ដែលបានផ្តល់ថវិកាសំរាប់ការរៀបចំចងក្រងសៀវភៅនេះ ។

Funds for this field guide were provided by The British Embassy, Phnom Penh and the World Bank executed PHRD Project preparation grant for the World Bank/GEF Biodiversity and Protected Areas Management Project. Additional copies have been made possible with funding from the CY 99 Environment Component of the World Bank/Netherlands Partnership Programme, through the IUCN Regional Biodiversity Programme for South and Southeast Asia.

THE WORLD BANK

BRITISH AID

IUCN
The World Conservation Union

JSRC PRINTING HOUSE

Printed by JSRC Printing House, Phnom Penh


# សៀវភៅថនិកសត្វប្រទេសកម្ពុជា


ចងក្រងដោយ :

**ម៉ែន សូរិយន់ កែវ អូម៉ាលីស្ស ចក់ សុខវិជ្ជបុត្រ**

ជំនួយការបន្ថែមដោយ :

**រ័ត្ន ប៊ុនធឿន** — **ឈាង ដានី**

**ហួត ពិសិដ្ឋ** — **ប៊ី សេងលៀង**

**ព្រំ សុវណ្ណា**



បោះពុម្ពដោយ :

- **នាយកដ្ឋានរុក្ខា-ប្រមាញ់**
- **នាយកដ្ឋានការពារអភិរក្សធម្មជាតិ**
- **អង្គការសមាគមអភិរក្សសត្វព្រៃ**

ភ្នំពេញ, កម្ពុជា

ខែ ឧសភា ឆ្នាំ ២០០០


# Mammals of Cambodia


**Compiled by:**

Men Soriyun, Keo Omaliss, Chak Sokhavicheaboth.

**With contributions by:**

Roth Bunthoeun, Hout Piseth, Prum Sovanna, Chheang Dany and By Seng Leang.



**Published by:**

The Department of Forestry and Wildlife
The Department of Nature Conservation and Protection
and the Wildlife Conservation Society Cambodia Program.

**Phnom Penh, Cambodia.**
**May, 2000.**

WCS
WILDLIFE CONSERVATION SOCIETY

# ៦០.រមាស(កុយមួយ)

**Javan Rhinoceros**
***Rhinoceros sondaicus***

**ទំហំ** : ក្បាល-ដងខ្លួន : ៣.០០០-៣.២០០ មម . កំពស់ត្រង់ស្មា : ១.៦០០-១.៨០០ មម. ទំងន់ : ១.៥០០-២.០០០ គក្រ ។

**ភិនភាគ** : រមាសមានស្បែកក្រាស់ និងមានផ្ទាំងផ្នត់៣ ផ្នត់ទី១ នៅផ្នែកខាងមុខស្មា ផ្នត់ទី២ នៅផ្នែកខាងក្រោយស្មា និងផ្នត់ទី៣ ចាប់ពីចង្កេះទៅក្រោមកាត់តាមជើងក្រោយមើលទៅដូចជាអាវក្រោះ ។ ស្បែកវារលីងមានពណ៌ប្រផេះ ។ រមាសមានជើងខ្លីៗតែរឹងមាំណាស់ ជើងនីមួយៗរបស់វាមានម្រាម ៣ ។ វាមានដុះកុយមួយនៅលើខ្នងច្រមុះរបស់វា ។

**ជីវសាស្ត្រ** : រមាសចូលចិត្តរស់នៅតាមព្រៃស្តុក ដែលមានទឹកគ្រប់គ្រាន់ វាចូលចិត្តដេកននៀលលេងភក់។ នៅរដូវបន្តពូជ រមាសរស់នៅជាគូ រមាសឈ្មោលចូលចិត្តចេញដើរឆ្ងាយៗ តែវាក៏ត្រឡប់មករកជំរករបស់វាវិញតាមផ្លូវដដែលដែលវាចាកចេញ ឯរមាសញីចូលចិត្តនៅការពារជំរក ។ វាមានបបូរមាត់ខាងលើធំ បង្កលក្ខណៈងាយស្រួលដល់ការទាញយកមែកឈើ និង ស្លឹកឈើដាក់បញ្ចូលទៅក្នុងមាត់ ។ រមាសចិញ្ចឹមកូនដោយទឹកដោះ ពរពោះរហូតដល់ ១៦-១៨ខែ កើតកូនបាន ១ ក្នុងមួយលើក ។ កូនរមាសបៅដោះមេវា រយៈពេល ១ឆ្នាំ តែមេរបស់វានឹងនៅមើលថែកូនរហូតដល់ធំពេញវ័យ ។ រមាសអាចបង្កាត់ពូជបាននៅ ពេលរមាសញីមានអាយុពី ៣-៤ ឆ្នាំ និងរមាសឈ្មោលចាប់ពី អាយុ ៦ឆ្នាំ ។

**របាយ និង ស្ថានភាព** : រមាសមានរស់នៅកម្ពុជាជាយូរមកហើយ ឈ្មោះតំបន់មួយចំនួនក្នុងប្រទេសកម្ពុជាយើង បានយកឈ្មោះរមាសមកដាក់ ដូចជា : ក្បាលរមាស (ខេត្តកំពត) រមាសហែក(ខេត្តស្វាយរៀង) ស្តុកអាចម៍រមាស(ខេត្តកំពង់ឆ្នាំង) នេះគឺជាភស្តុតាងយ៉ាងច្បាស់ដែលបញ្ជាក់ថា សត្វរមាសពិតជាធ្លាប់រស់ នៅព្រះរាជាណាចក្រកម្ពុជា ។ បើទោះបីជាគេពុំដែលមានការអះអាងពីវត្តមានជាក់លាក់ក៏ដោយ ។ តាមការអះអាងពីប្រជាជនមូលដ្ឋានថា វាអាចមានរស់នៅតំបន់មួយចំនួនដូចជា ខេត្តក្រចេះ ខេត្តកំពង់ចាម និង តំបន់ភ្នំក្រវាញជាដើម ។ វាត្រូវបានហាមឃាត់ការបរបាញ់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ និងចុះក្នុងបញ្ជីក្រហម IUCN (CT) ជាប្រភេទទទួលរងការគំរាមកំហែងលើពិភពលោក និង ស្ថិតក្នុង ឧបសម្ព័ន្ធ ទី១ របស់អនុសញ្ញា CITES ។



